**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ៦៤៨ ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធី លក្ខខណ្ឌនៃការសុំ ការផ្តល់ ការប្រើប្រាស់ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានឃើញ អនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញ អនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- បានឃើញ អនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ ស្តីពីការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា
- បានឃើញ អនុក្រឹត្យលេខ ២៧០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១ ស្តីពីការកែសម្រួលមាត្រា១ និងមាត្រា៧ នៃអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- យោងតាមការចាំបាច់ក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

## សម្រេច

**ប្រការ ១ :** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុពី១៥ឆ្នាំឡើងទៅ ត្រូវទៅធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនៅសាលាឃុំ សង្កាត់ ឬនៅតាមស្ថានីយ៍ចល័តនៃឃុំ សង្កាត់ ឬស្ថានីយ៍អចិន្ត្រៃយ៍ នៃអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ របស់ខ្លួន ។

ប្រការ២ ៈ មន្ត្រីនគរបាលមានសមត្ថកិច្ច ត្រូវពិនិត្យសំណុំបែបបទសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនប្រជាពលរដ្ឋណា ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម ៈ

- មានសំបុត្រកំណើត ដែលបានបញ្ជាក់ថាសញ្ជាតិខ្មែរ
- មានសៀវភៅស្នាក់នៅ "ក២" ឬសៀវភៅគ្រួសារ "ក៤" ឬ
- មានសេចក្តីសម្រេចទទួលស្គាល់តាមផ្លូវច្បាប់ អំពីការធ្វើសញ្ជាតិតូបនីយកម្ម ឬការទាមទារសញ្ជាតិ ឬ
- សាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថា ជននោះកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ ឬ
- ឯកសារ ឬភស្តុតាងជាផ្លូវការដែលបញ្ជាក់ថា សាមីជនកើតមកពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ ។

<u>លើកលែងតែ</u> ៈ

- កំពុងបំពេញជាបព្វជិតក្នុងព្រះពុទ្ធសាសនា
- ជនកំពុងអនុវត្តទោសតាមសាលក្រម ឬសាលដីការបស់តុលាការ
- ជនវិកលចរិក
- ជនកំពុងឋិតក្នុងមណ្ឌលអប់រំកែប្រែ
- ជនដែលមានឯកសារផ្លូវការពុំទាន់គ្រប់គ្រាន់ថាខ្លួនមានសញ្ជាតិខ្មែរ ។

ប្រការ៣ ៈ សាមីខ្លួនម្នាក់ៗ ត្រូវបំពេញសំណុំលិខិតតាមគំរូឯកភាពរបស់ក្រសួងមហាផ្ទៃ និងត្រូវ ៈ

- រាយការណ៍ចុះឈ្មោះត្រឹមត្រូវ ផ្តល់ព័ត៌មានច្បាស់លាស់ តាមខ្លឹមសារសលាកប័ត្រសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- ផ្តិតក្រយៅម្រាមដៃ ថតរូប ចុះហត្ថលេខា
- បង់ប្រាក់ថ្លៃអាករអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ តាមប្រកាសរបស់អន្តរក្រសួង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ។

ប្រការ៤ ៈ សមត្ថកិច្ចដែលមានភារកិច្ច ធ្វើសម្រង់បញ្ជីឈ្មោះ បំពេញបែបបទ និងចុះហត្ថលេខាលើបញ្ជីរាយនាមប្រជាពលរដ្ឋដែលត្រូវផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ៈ

- ប្រធានភូមិ នគរបាលប៉ុស្តិ៍រដ្ឋបាល ស្មៀនឃុំ សង្កាត់ សហការធ្វើសម្រង់បញ្ជីឈ្មោះប្រជាពលរដ្ឋដែលមានអាយុពី១៥ឆ្នាំឡើង ចេញពីសំបុត្រកំណើត សៀវភៅស្នាក់នៅ "ក២" ឬសៀវភៅគ្រួសារ "ក៤" ឬឯកសារផ្សេងទៀតដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ និងពិនិត្យឱ្យបានត្រឹមត្រូវលើអក្ខរាវិរុទ្ធ ព្រមទាំងផ្ទៀងផ្ទាត់តាមខ្លឹមសារដែលបានស្រង់ចូលក្នុងទម្រង់បែបបទដែលក្រសួងបានផ្តល់ឱ្យ មុននឹងបញ្ជូនឱ្យប្រធាននគរបាលប៉ុស្តិ៍រដ្ឋបាល និងមេឃុំ ចៅសង្កាត់ពិនិត្យចុះហត្ថលេខា ។
- អធិការនគរបាលក្រុង ស្រុក ខណ្ឌ ពិនិត្យ និងចុះហត្ថលេខាលើសម្រង់បញ្ជីឈ្មោះប្រជាពលរដ្ឋដែលមានអាយុពី១៥ឆ្នាំឡើង រួចបញ្ជូនទៅអភិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យសម្រេច។
- ស្នងការនគរបាលរាជធានី ខេត្ត ត្រូវចាត់មន្ត្រីជំនាញ បំពេញបែបបទ៥ (ប្រមូលទិន្នន័យ)

នៅតាមស្ថានីយ៍ចល័ត ឬស្ថានីយ៍អចិន្ត្រៃយ៍រួចបញ្ជូនទិន្នន័យមកមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ហើយធ្វើបញ្ជីអ្នកដែលបានបំពេញបែបបទរួច ដើម្បីសុំការពិនិត្យសម្រេចពីអភិបាលរាជធានី ខេត្ត ទើបបញ្ជូនទិន្នន័យមកឱ្យមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យរបស់ក្រសួងមហាផ្ទៃ ធ្វើការបោះពុម្ព និងផលិតចេញជាសន្លឹកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

ប្រការ៥ : អភិបាលរាជធានី ខេត្ត មានភារកិច្ចទទួលខុសត្រូវដឹកនាំ ចាត់តាំងអនុវត្តការងារផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងជាអ្នកត្រួតពិនិត្យសម្រេចចុងក្រោយលើបញ្ជីឈ្មោះអ្នកដែលត្រូវផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។ ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលបានបំពេញបែបបទសុំធ្វើរហូតដល់ថ្ងៃចែកជូនប្រជាពលរដ្ឋប្រើប្រាស់ ។

ប្រការ៦ : អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានសុពលភាព១០ ឆ្នាំ។ មុនពេលអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអស់សុពលភាព ៣០ ថ្ងៃ សាមីខ្លួនត្រូវសុំធ្វើសាជាថ្មីឡើងវិញ "ទុតិយតា" ។ នីតិវិធីនៃការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទុតិយតា ត្រូវបំពេញសំណុំលិខិតដូចមានចែងក្នុងប្រការ ៣ នៃប្រកាសនេះ ។

ប្រការ៧ : អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលសាមីខ្លួនបានទទួលរួចហើយ ត្រូវប្រើប្រាស់ និងថែរក្សាឱ្យបានល្អ មានការប្រុងប្រយ័ត្នកុំឱ្យបាត់ ឬខូច និងត្រូវយកជាប់តាមខ្លួននៅពេលធ្វើដំណើរ ដើម្បីសម្គាល់ថាជាពលរដ្ឋខ្មែរ និងប្រើប្រាស់ក្នុងការបំពេញបែបបទផ្សេងៗ តាមការកំណត់នៃច្បាប់ និងបទដ្ឋាននានាជាធរមាន ដូចជា : ចុះឈ្មោះ ឬឈរឈ្មោះបោះឆ្នោត សុំរៀបអាពាហ៍ពិពាហ៍ សុំធ្វើសំបុត្រកំណើតកូន សុំធ្វើការងារ សុំប្រកបអាជីវកម្ម សុំធ្វើលិខិតឆ្លងដែន សុំធ្វើម្ចាស់កម្មសិទ្ធិលើអចលនទ្រព្យ ទំនាក់ទំនងធនាគារ ព្រមទាំងកិច្ចសន្យាទិញ-លក់ ផ្សេងៗ ។ល។ និង ។ល។

ប្រការ៨ : ត្រូវបានដកហូតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជាបណ្តោះអាសន្ន និង ឬ ជាស្ថាពរក្នុងករណី :

- ជនត្រូវចាប់ខ្លួនបញ្ជូនទៅពន្ធនាគារ ឬមានដីកាឃុំខ្លួនបណ្តោះអាសន្ន
- ជនដែលមានសាលក្រម ឬសាលដីការបស់តុលាការបង្គាប់ឱ្យដកហូត
- ជនគ្មានសញ្ជាតិខ្មែរ តែមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

ប្រការ៩ : ជនដែលបាត់ ឬ ខូចអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវប្តឹងដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលនៅឃុំ-សង្កាត់ដែលកើតឡើងការបាត់ ឬខូច មិនលើស២៤ ម៉ោងបន្ទាប់ពីដឹងថាបាត់ ឬខូច ។ ក្នុងករណីបើការបាត់ ឬខូចកើតឡើងក្រៅឃុំ សង្កាត់របស់ខ្លួន សាមីខ្លួនត្រូវជូនដំណឹងដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលនៅឃុំ សង្កាត់ដែលខ្លួនកំពុងរស់នៅ មិនលើស៤៨ ម៉ោងបន្ទាប់ពីវិលត្រឡប់មកដល់លំនៅដ្ឋានវិញ។

ករណីដែលសមត្ថកិច្ចពិនិត្យឃើញថា ពិតជាមានការបាត់ ឬខូចប្រាកដមែន ហើយជននោះពិតជាមានឈ្មោះក្នុងបញ្ជីត្រឹមត្រូវ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ "ទុតិយតា" នឹងត្រូវបានផ្តល់

ជូនជាថ្មីក្រោយរយៈពេលមួយខែ គិតពីថ្ងៃដែលបានទទួលបណ្តឹង ឬដំណឹង និងសាមីខ្លួនបានបំពេញសំណុំលិខិតគ្រប់គ្រាន់ ។

**ប្រការ១០ :** ជនណាដែល :

- រាយការណ៍ចុះឈ្មោះ ផ្តល់ព័ត៌មានខុសពីការពិត ក្នុងសំណុំបែបបទសុំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។
- គ្មានសញ្ជាតិខ្មែរ ប៉ុន្តែកាន់កាប់ ឬប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។
- ក្លែង កោស លុប ឱ្យអ្នកដទៃខ្ចី ឬសរសេរត្រួតក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។
- មានចេតនាជួយធ្វើសម្រង់បញ្ជីអ្នកដែលត្រូវផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ ជួយបំពេញសំណុំបែបបទ និង ឬ សម្រេចផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឱ្យជនដែលគ្មានសញ្ជាតិខ្មែរ ។

ត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

**ប្រការ១១ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ១២ :** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និង និងហិរញ្ញវត្ថុ អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ អភិបាលរាជធានី ខេត្ត និងបណ្តាអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិនា ឆ្នាំ២០១២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**<u>ចម្លងជូន</u> :**

- ...លេខាធិការដ្ឋានព្រឹទ្ធសភា
- ...លេខាធិការដ្ឋានរដ្ឋសភា
- ...គណៈរដ្ឋមន្ត្រី
- ...ល័យសម្តេចអគ្គមហាសេនាបតី
- ...ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ...ក្រសួង ស្ថាប័ន
- ...- កាលប្បវត្តិ